### ជំពូកទី ១១
### អវសានប្បញ្ញត្តិ

**មាត្រា ៤៦ .-**

កម្មប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយទៅនឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៤៧ .-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី០៣ ខែមិនា ឆ្នាំ២០០០
ក្នុងព្រះបរមនាម និង តាមព្រះរាជគ្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី
ហត្ថលេខា
**ជា ស៊ីម**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
ហត្ថលេខា
**ហ៊ុន សែន**

បានជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី
ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ហត្ថលេខា
**គាត ឈន់**

★★★

## ២- ព្រះរាជក្រឹត្យ

### ព្រះរាជក្រឹត្យ ជស/រកត/០៣០០/១១៦
### ស្តីពីលក្ខន្តិកៈដោយឡែក
### នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល

**យើង**

**ព្រះបាទសម្តេចព្រះនរោត្តមសីហនុ**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

....

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទទួលការយល់ព្រមពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០០

**ត្រាស់បង្គាប់**

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .-**

ត្រូវបានបង្កើតក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលដែលត្រូវបានចាត់ថ្នាក់ក្នុងប្រភេទ ក ដូចបានចែងក្នុងមាត្រា៣ នៃព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ ។

**មាត្រា ២ .-**

ក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ដែលជាកម្មវត្ថុនៃលក្ខន្តិកៈដោយឡែកសំរាប់ក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលនេះ ស្ថិតនៅក្រោមឱវាទរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ដែលប្រមូលផ្តុំមន្ត្រីរាជការធ្វើការងាររដ្ឋបាលសំរាប់បណ្តាក្រសួង ស្ថាប័ននានា។ ឯការវិវត្តន៍របស់មន្ត្រីម្នាក់ៗ គឺស្ថិតនៅក្រោមក្រសួង ស្ថាប័នសាមី។

មិនត្រូវបានអនុញ្ញាតអោយបង្កើតក្របខ័ណ្ឌសំរាប់ធ្វើការងារគ្រប់គ្រងរដ្ឋបាលផ្សេងពីក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលឡើយ លើកលែងតែក្រសួងមហាផ្ទៃ ។

**មាត្រា ៣ .-**

មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល មានឧបនិស្ស័យសំរាប់កាន់មុខតំណែងដឹកនាំ និងទទួលខុសត្រូវធ្វើអធិការកិច្ច ធ្វើការសិក្សា និងផ្តល់យោបល់ ក្នុងអង្គភាពរដ្ឋបាល គតិយុត្ត សេដ្ឋកិច្ច បច្ចេកទេស និងសង្គមកិច្ច នៃ រដ្ឋបាលកណ្តាល និងខេត្តក្រុង ស្របតាមមាត្រា ៣ នៃព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះ ថ្ងៃទី០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ ។ មន្ត្រីក្នុងក្របខ័ណ្ឌក៏មានឧបនិស្ស័យសំរាប់បំពេញមុខតំណែងនៅក្នុងគ្រឹះស្ថានសាធារណៈរដ្ឋបាលផងដែរ ។

## ជំពូកទី២
## ឋានន្តរស័ក្តិ និង មុខតំណែង

មាត្រា ៤ ._

ក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល មាន ៣ ឋានន្តរស័ក្តិ ៖

-ឧត្តមមន្ត្រី មាន ៦ នាក់

-វរៈមន្ត្រី មាន ១០ នាក់

-អនុមន្ត្រី មាន ១៤ នាក់ ។

មាត្រា ៥ ._

មន្ត្រីរាជការក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី មានឧបនិស្ស័យសំរាប់កាន់មុខតំណែងជា ៖

-អគ្គនាយក

-អគ្គាធិការ

-និងមុខតំណែងឯទៀតដែលមានថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងអង្គការលេខនៃរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន ។

មន្ត្រីរាជការក្នុងឋានន្តរស័ក្តិ វរៈមន្ត្រី មានឧបនិស្ស័យសំរាប់កាន់មុខតំណែងជា ៖

-អគ្គនាយករង

-អគ្គាធិការរង

-ប្រធាននាយកដ្ឋានក្នុងរដ្ឋបាលកណ្តាល

-និងមុខតំណែងឯទៀតដែលមានថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងអង្គភាពលេខនៃរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន ។

មន្ត្រីរាជការក្នុងឋានន្តរស័ក្តិអនុមន្ត្រី មានឧបនិស្ស័យសំរាប់កាន់មុខតំណែងជា ៖

-អនុប្រធាននាយកដ្ឋានក្នុងរដ្ឋបាលកណ្តាល

-ប្រធានមន្ទីរនៅខេត្ត ក្រុង

-និងមុខតំណែងឯទៀតដែលមានថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងអង្គការលេខនៃរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន ។

## ជំពូកទី ៣
## ការជ្រើសរើស

មាត្រា ៦ ._

ការជ្រើសរើសចូលក្នុងក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ត្រូវធ្វើឡើងតាមរយៈការប្រឡងប្រជែងក្នុងចំណោមបេក្ខជនជាមន្ត្រីរាជការ និង ឬក្នុងចំណោមនិស្សិត ។ ចំនួនតំណែងក្នុងការជ្រើសរើសសំរាប់

បេក្ខជនជាមន្ត្រីរាជការ និងសំរាប់បេក្ខជនជានិស្សិត ត្រូវកំណត់ឡើង [illegible] តាមសំណើរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

**មាត្រា ៧ .-**

ការប្រឡងប្រជែងក្នុងចំណោមនិស្សិត ត្រូវបើកចំហចំពោះបេក្ខជនដែលមានអាយុច្រើនបំផុត ៣០ ឆ្នាំគិតមកដល់ថ្ងៃប្រឡង ហើយដែលមានសញ្ញាប័ត្រទាបបំផុតសមមូលបរិញ្ញាប័ត្រ ។

ការប្រឡងប្រជែងក្នុងចំណោមមន្ត្រីរាជការត្រូវបើកចំហចំពោះមន្ត្រីទាំងឡាយ ដែលស្ថិតយ៉ាងតិចបំផុតក្នុងថ្នាក់លេខ ១១ របស់ក្របខ័ណ្ឌប្រភេទ ខ និងមានអាយុច្រើនបំផុត ៤៥ ឆ្នាំ ។ ចំពោះមន្ត្រីក្នុងក្របខ័ណ្ឌដែលមានសញ្ញាប័ត្រសមមូលនឹងបរិញ្ញាប័ត្រអាចប្រឡងប្រជែងចូលក្របខ័ណ្ឌនេះបាន ដោយពុំគិតលក្ខខ័ណ្ឌឋានន្តរស័ក្តិ និងប្រភេទក្របខ័ណ្ឌឡើយ ហើយមានអាយុច្រើនបំផុត ៤៥ ឆ្នាំ ។

## ជំពូកទី ៤

## ការបណ្តុះបណ្តាលដំបូង កម្មសិក្សាសាកល្បង និងការតាំងស៊ប់

**មាត្រា ៨ .-**

បេក្ខជនដែលត្រូវបានជ្រើសរើសតាមរយៈការប្រឡងប្រជែងក្នុងចំណោមមន្ត្រីរាជការ និងឬក្នុងចំណោម និស្សិតមានឋានៈជាសិស្សមន្ត្រីគ្រប់គ្រងរដ្ឋបាល ហើយត្រូវទទួលការបណ្តុះបណ្តាលដំបូងនៅសាលាភូមិន្ទរដ្ឋបាល ។

**មាត្រា ៩ .-**

បន្ទាប់ពីការបណ្តុះបណ្តាលដំបូង សិស្សមន្ត្រីគ្រប់គ្រងរដ្ឋបាលត្រូវបានចាត់អោយទៅបំពេញការងារតាមក្រសួង ស្ថាប័ននានាហើយត្រូវបានតែងតាំងជាមន្ត្រីគ្រប់គ្រងរដ្ឋបាលកម្មសិក្សា ដោយប្រកាសរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

មន្ត្រីគ្រប់គ្រងរដ្ឋបាលកម្មសិក្សាទាំងនេះ ត្រូវឆ្លងកាត់កម្មសិក្សាមួយដែលមានរយៈពេលដូចខាងក្រោមនេះ ៖

១-១២ ខែ ចំពោះមន្ត្រីដែលត្រូវបានជ្រើសរើសចេញមកពីនិស្សិត ។

២-៦ ខែ ចំពោះមន្ត្រីដែលត្រូវបានជ្រើសរើសចេញមកពីមន្ត្រីរាជការ ហើយដែលពីមុននេះពុំស្ថិតក្នុងក្របខ័ណ្ឌក្រមការ ។

ចំពោះមន្ត្រីដែលត្រូវបានជ្រើសរើសចេញមកពីមន្ត្រីរាជការ ហើយដែលពីមុននេះស្ថិតក្នុងក្របខ័ណ្ឌក្រមការពុំចាំបាច់ឆ្លងកាត់កម្មសិក្សាសាកល្បងឡើយ ។

ក្រោយពេលធ្វើកម្មសិក្សាសាកល្បងមន្ត្រីដែលចែងក្នុងចំណុចទី១ និងទី២ ខាងលើ ត្រូវបានតាំងស៊ប់ក្នុងឋានន្តរស័ក្តិអនុមន្ត្រី ។ ក្នុងករណីពិសេសអាចត្រូវបានអនុញ្ញាតអោយធ្វើកម្មសិក្សាបន្តបន្ថែម ដែលមានរយៈពេលអតិបរមាត្រឹម១២ ខែចំពោះមន្ត្រីដែលមានចែងក្នុងចំណុចទី១ និង៦ខែ ចំពោះមន្ត្រីដែលមានចែងក្នុងចំណុចទី២ ។ មន្ត្រីដែលពុំបានទទួលជោគជ័យក្នុងការធ្វើកម្មសិក្សាបន្ថែមនេះ ត្រូវលុបឈ្មោះចោល

ប្រសិនបើចេញមកពីនិស្សិត ឬមួយបញ្ចូលទៅក្របខ័ណ្ឌដើមរបស់ខ្លួនវិញប្រសិនបើចេញមកពីមន្ត្រីរាជការ ដោយគិតបញ្ចូល អតីតភាពការងារ ។ ករណីខាងលើទាំងនេះត្រូវសំរេចដោយប្រកាសរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ក្រោយពីមានសំណើរបស់ក្រសួង ស្ថាប័នសាមី ដោយបញ្ជាក់នូវមូលហេតុ ហើយត្រូវធ្វើឡើង ក្នុងរយៈពេលយ៉ាងយូរ ៣ ខែ ក្រោយការបញ្ចប់កម្មសិក្សា ។

មន្ត្រីគ្រប់គ្រងរដ្ឋបាល ដែលត្រូវបានជ្រើសរើសតាមការប្រឡងប្រជែងក្នុងចំណោមនិស្សិត ត្រូវបញ្ចូលទៅក្នុងថ្នាក់លេខ ១៥ នៃឋានន្តរស័ក្តិអនុមន្ត្រី ។

មន្ត្រីគ្រប់គ្រងរដ្ឋបាល ដែលត្រូវបានជ្រើសរើសតាមការប្រឡងប្រជែងក្នុងចំណោម មន្ត្រីរាជការ ត្រូវបញ្ចូលទៅក្នុងថ្នាក់ដែលមានសន្ទស្សន៍បៀវត្សខ្ពស់បើបន្ទាប់ពីសន្ទស្សន៍ចាស់របស់សាមីខ្លួន ។

ការតាំងស៊ប់ក្នុងឋានន្តរស័ក្តិ អនុមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យ ។

## ជំពូកទី ៥

## ការតែងតាំង

**មាត្រា ១០ ._**

ក្រោយពេលត្រូវបានតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលរួចហើយ មន្ត្រីគ្រប់គ្រងរដ្ឋបាលទាំងនេះ អាចត្រូវបានតែងតាំងក្នុងមុខតំណែងទំនេរណាមួយដូចមានចែងក្នុងមាត្រា ៥ ខាងលើ ស្របតាមឋានន្តរស័ក្តិរបស់ខ្លួន តាមបែបបទដូចបានកំណត់ក្នុងមាត្រា ១៤ និងមាត្រាបន្តបន្ទាប់នៃព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ។

**មាត្រា ១១ ._**

មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលអាចផ្លាស់ប្តូរពីក្រសួងស្ថាប័នមួយទៅក្រសួងស្ថាប័នមួយទៀតតាមការស្នើសុំរបស់សាមីខ្លួន ឬតាមតម្រូវការការងារ ដោយមានការឯកភាពរបស់ក្រសួងស្ថាប័នសាមីទាំងពីរ និងដោយមានការយល់ព្រមពីរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ហើយត្រូវសំរេចដោយប្រកាស ឬអនុក្រឹត្យ ឬព្រះរាជក្រឹត្យ ។

**ការផ្លាស់ប្តូរនេះ ជាគោលការណ៍អាស្រ័យដោយតំណែងដែលមាននៅទំនេរក្នុងក្រសួង ស្ថាប័នមួយទៀត ឬដោយសំណូមពរការងារចាំបាច់ ។**

## ជំពូកទី ៦

## ការតម្លើងថ្នាក់ និង ការតម្លើងឋានន្តរស័ក្តិ

**មាត្រា ១២ ._**

មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលត្រូវបានតម្លើងថ្នាក់ទៅតាមល័ក្ខខ័ណ្ឌដូចបានចែងក្នុងមាត្រា២០ និងមាត្រាបន្តបន្ទាប់ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ។

លក្ខណៈសម្បត្តិជាមូលដ្ឋានដែលត្រូវពិនិត្យតម្លើងថ្នាក់មានដូចខាងក្រោម ៖

-មានគំនិតផ្តួចផ្តើម និងច្នៃប្រឌិត

-មានស្មារតីទទួលខុសត្រូវ

-យកចិត្តទុកដាក់ដល់ផលប្រយោជន៍ជាតិ

-មានប្រសិទ្ធភាពក្នុងការដឹកនាំ

-មានសីលធម៌ល្អ

ការឡើងថ្នាក់ នៃមន្ត្រីរាជការក្នុងក្របខ័ណ្ឌនេះ ត្រូវគិតក្នុងសមាមាត្រ ៣ ភាគ ៤ តាមវេនជ្រើសរើស និង ១ ភាគ ៤ តាមវេនអតីតភាព ។

ចំពោះការតម្លើងថ្នាក់ ៖

-ការតម្លើងថ្នាក់ នៅក្នុងឋានន្តរស័ក្តិ ឧត្តមមន្ត្រីត្រូវសំរេចដោយព្រះរាជក្រឹត្យ

-ការតម្លើងថ្នាក់ នៅក្នុងឋានន្តរស័ក្តិ វរៈមន្ត្រីត្រូវសំរេចដោយអនុក្រឹត្យ

-ការតម្លើងថ្នាក់ នៅក្នុងឋានន្តរស័ក្តិ អនុមន្ត្រីត្រូវសំរេចដោយប្រកាសរបស់ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

**មាត្រា ១៣ .-**

គោលការណ៍នៃការតម្លើងឋានន្តរស័ក្តិត្រូវតម្លើងទៅក្នុងថ្នាក់ដំបូង នៃឋានន្តរស័ក្តិខ្ពស់លើបន្ទាប់ ឬក្នុងករណីចាំបាច់ត្រូវតម្លើងទៅក្នុងថ្នាក់ដែលស្របជាមួយសន្ទស្សន៍ខ្ពស់លើបន្ទាប់ ពីសន្ទស្សន៍ចាស់របស់មន្ត្រីសាមី ។

ការតម្លើងឋានន្តរស័ក្តិត្រូវអនុវត្តអោយបានស្របជាមួយចំនួនតំណែងដែលមានទំនេរ នៅក្នុងឋានន្តរស័ក្តិនោះ ហើយត្រូវធ្វើតាមរយៈការចុះឈ្មោះក្នុងតារាងតម្លើងឋានន្តរស័ក្តិ ឬ តាមរយៈការប្រឡងប្រជែងមួយតាមរយៈការបណ្តុះបណ្តាលរយៈពេលវែងនៅក្នុង ឬ ក្រៅប្រទេស ។

ការតម្លើងឋានន្តរស័ក្តិអនុមន្ត្រីទៅវរៈមន្ត្រីត្រូវសំរេចដោយអនុក្រឹត្យ ហើយការតម្លើងឋានន្តរស័ក្តិវរៈមន្ត្រី ទៅឧត្តមមន្ត្រី ត្រូវសំរេចដោយព្រះរាជក្រឹត្យ ។

**មាត្រា ១៤ .-**

អាចតម្លើងទៅក្នុងឋានន្តរស័ក្តិវរៈមន្ត្រី គឺមន្ត្រីទាំងឡាយដែលបានឡើងដល់ថ្នាក់លេខ ១១ នៃឋានន្តរស័ក្តិអនុមន្ត្រី ។ អាចតម្លើងទៅក្នុងឋានន្តរស័ក្តិឧត្តម គឺមន្ត្រីទាំងឡាយដែលបានឡើងដល់ថ្នាក់លេខ ៧ ឋានន្តរស័ក្តិវរៈមន្ត្រី ។

ការតម្លើងទៅក្នុងឋានន្តរស័ក្តិមួយខ្ពស់ជាង អាចផ្តល់ឧបនិស្ស័យដល់មន្ត្រីសាមីសំរាប់កាន់មុខតំណែងស្របតាមឋានន្តរស័ក្តិថ្មីនោះ ដូចបានកំណត់ក្នុងមាត្រា ៥ នៃលក្ខន្តិកៈដោយឡែកនេះ ។

**មាត្រា ១៥ .-**

សន្ទស្សន៍សំរាប់ថ្នាក់ក្នុងឋានន្តរស័ក្តិនីមួយៗ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងតំលៃឯកតាសន្ទស្សន៍ព្រមទាំងរបបលាភការផ្សេងៗទៀត ត្រូវកំណត់ដោយព្រះរាជក្រឹត្យដោយឡែក ។

## ជំពូកទី ៧

## បទប្បញ្ញត្តិដោយឡែក

មាត្រា ១៦ ._

មន្ត្រីនៃក្របខ័ណ្ឌគ្រប់គ្រងរដ្ឋបាលបំពេញការងាររដ្ឋបាលរហូតដល់អាយុ ៦០ ឆ្នាំ ទើបចូលនិវត្តន៍ ។

ចំពោះការដាក់អោយចូលនិវត្តន៍ ៖

-ការដាក់អោយចូលនិវត្តន៍នៅក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី ត្រូវសំរេចដោយព្រះរាជក្រឹត្យ

-ការដាក់អោយចូលនិវត្តន៍នៅក្នុងឋានន្តរស័ក្តិវរៈមន្ត្រី ត្រូវសំរេចដោយអនុក្រឹត្យ

-ការដាក់អោយចូលនិវត្តន៍នៅក្នុងឋានន្តរស័ក្តិអនុមន្ត្រី ត្រូវសំរេចដោយប្រកាសរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

មាត្រា ១៧ ._

មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ដែលមានសញ្ញាប័ត្រខ្ពស់ជាងបរិញ្ញាប័ត្រ ត្រូវបានតម្លើងថ្នាក់មួយថ្នាក់ជាស្វ័យប្រវត្តិ ។

មាត្រា ១៨ ._

សញ្ញាស័ក្តិនិងឯកសណ្ឋានសំរាប់មន្ត្រីគ្រប់គ្រងរដ្ឋបាល ត្រូវកំណត់ដោយព្រះរាជក្រឹត្យមួយដោយឡែក ។

## ជំពូកទី ៨

## អន្តរប្បញ្ញត្តិ

មាត្រា ១៩ ._

ចំនួនដំបូងនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ត្រូវកសាងចេញពីសមាហរណកម្មមន្ត្រីទាំងឡាយដែលបច្ចុប្បន្នកំពុងបំពេញមុខតំណែង និងមុខងារពិតប្រាកដរបស់ក្របខ័ណ្ឌក្នុងរដ្ឋបាលកណ្តាល និងខេត្តក្រុង ។

## ជំពូកទី ៩

## អវសានប្បញ្ញត្តិ

មាត្រា ២០ ._

រាល់បទប្បញ្ញត្តិណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ២១ .-**

នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ ក្នុងព្រះបរមនាម និងតាមព្រះរាជបន្ទូលបង្គាប់

ព្រះមហាក្សត្រ ឡាយព្រះហស្ថលេខា

ប្រមុខរដ្ឋស្តីទី

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហត្ថលេខា

ជា ស៊ីម

ហ៊ុន សែន

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

ហត្ថលេខា

ពៅ ប៊ុនធិន

***

## ព្រះរាជក្រឹត្យ ជស/រកត/០៣០០/១១៧

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

****

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រៈ អោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា